# របាយការណ៍

# សន្និបាតបូកសរុបលទ្ធផល ការងារព័ត៌មាន និងសោតទស្សន៍ ឆ្នាំ ២០០៩ និងទិសដៅការងារសម្រាប់អនុវត្ត ឆ្នាំ ២០១០

ឆ្នាំ ២០០៩ គឺជាឆ្នាំដែលត្រូវបានកត់សម្គាល់នូវព្រឹត្តិការណ៍សំខាន់ៗ ទាក់ទាញនូវការចាប់អារម្មណ៍ ពី ប្រជាជនខ្មែរទាំងក្នុងនិងក្រៅប្រទេស រួមទាំងពីសំណាក់មជ្ឈដ្ឋានអន្តរជាតិនៅក្នុងតំបន់ និងពិភពលោកផង។ ព្រឹត្តិការណ៍លេចធ្លោដែលបានលើកកម្ពស់អត្តសញ្ញាណជាតិ និងមោទនភាពជាតិខ្មែរដ៏ល្បីរន្ទឺបំផុត ក្នុងប្រវត្តិសាស្ត្រគឺ៖

១- បន្តពីជោគជ័យ នៃការចុះបញ្ជីប្រាសាទព្រះវិហារ ជាបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៨ មក នៅឆ្នាំ ២០០៩ ព្រះរាជាណាចក្រកម្ពុជាយើង បានទទួលជោគជ័យ ដ៏ល្បីរន្ទឺថ្មីទៀតនៅលើឆាកអន្តរជាតិ ដោយមហាសន្និបាតលើកទី ១៧ របស់រដ្ឋភាគី ១៨៦ នៃអនុសញ្ញា ឆ្នាំ ១៩៧២ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ធម្មជាតិពិភពលោក ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការអង្គការផ្នែកអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការ សហប្រជាជាតិ ( UNESSCO ) នាទីក្រុងប៉ារីស ប្រទេសបារាំងនោះ បានបោះឆ្នោត និងប្រកាស**ប្រទេសកម្ពុជាជាប់ឆ្នោតជាសមាជិកគណៈកម្មការបេតិកភណ្ឌពិភពលោក** នៅថ្ងៃទី ២៦តុលា វេលាម៉ោង ២១ ម៉ោងនៅទីក្រុងប៉ារីស ត្រូវនឹងម៉ោង ៣ទៀបភ្លឺ (ម៉ោងនៅកម្ពុជា) ថ្ងៃទី ២៧ តុលា ។

២-ការវាយបំបាក់នូវអំនួតការទូត និងអំពើបង្កហេតុឈ្លានពានយ៉ាងកំរោលជាបន្តបន្ទាប់របស់ប្រទេសសៀមមកលើតំបន់ជុំវិញប្រាសាទព្រះវិហារ និងតំបន់ជាយដែនមួយចំនួនទៀតរបស់កម្ពុជា ចាប់តាំងពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៨ រហូតមកទល់បច្ចុប្បន្ន ។ ព្រឹត្តិការណ៍នេះ ក៏បានបង្ហាញឱ្យឃើញនូវការរីកចំរើនធំធាត់ និងឧត្តមគតិស្នេហាជាតិក្លាហានអង់អាចរបស់ប្រជារាស្ត្រខ្មែរ និងកងយោធពលខេមរភូមិន្ទ ក្នុងបុព្វហេតុការពារ បូរណភាពទឹកដី និងអធិបតេយ្យជាតិ ដ៏ពិសិដ្ឋរបស់ខ្លួន ។

៣-កម្ពុជាធានាបានយ៉ាងល្អប្រសើរ នូវស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងរក្សាបានលំនឹងសេដ្ឋកិច្ចសង្គម ទោះបីត្រូវទទួលរងនូវគ្រោះធម្មជាតិដោយសារព្យុះភ្លៀង នៅតាមបណ្តាខេត្តមួយចំនួនក្នុងប្រទេស និងទទួលរងនូវផលប៉ះពាល់ឥទ្ធិពលសេដ្ឋកិច្ចហិរញ្ញវត្ថុពិភពលោកក៏ដោយ ។

៤-វិស័យព័ត៌មាន និងសោតទស្សន៍ ក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងព័ត៌មាន បានពង្រីកនូវ សក្តានុពល និងវិសាលភាពរបស់ខ្លួនយ៉ាងសកម្ម ធ្វើឱ្យវិស័យនេះ មានការអភិវឌ្ឍន៍គួរកត់សម្គាល់ទាំងបរិមាណ និងគុណភាព ហើយមានសមត្ថភាពធានាបានពេញលេញ និងទូលំទូលាយនូវតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការផ្តល់ជូនប្រជាពលរដ្ឋនូវព័ត៌មានអំពីព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ ការអប់រំសង្គម និងការកម្សាន្តសប្បាយ ស្របតាមទិសស្លោក “ **ថ្មែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន** ” តាមរយៈប្រព័ន្ធផ្សព្វផ្សាយចម្រុះ ទាំងរដ្ឋឯកជន និងសង្គមស៊ីវិល ។

**I-ការងារដឹកនាំគ្រប់គ្រងវិស័យ ព័ត៌មាន និងសោតទស្សន៍** :

**១-សកម្មភាពថ្នាក់ដឹកនាំ :**

ដើម្បីជម្រុញដំណើរការងារឱ្យមានភាពល្អប្រសើរ ក្រសួងបានបើកកិច្ចប្រជុំប្រចាំឆមាស ដើម្បីបូកសរុបវាយ តម្លៃ និងដកបទពិសោធន៍ការងារផ្សព្វផ្សាយជាមួយនឹងបណ្តាមន្ទីរព័ត៌មាន រាជធានី-ខេត្តទាំងអស់ ពិសេសខេត្ត ដែលមានស្ថានីយវិទ្យុ-ទូរទស្សន៍ ។ ទន្ទឹមនឹងនេះដែរ ក្រសួងក៏បានសហការជាមួយក្រសួងការបរទេស និងសហ ប្រតិបត្តិការអន្តរជាតិ រៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន-សហភាពអឺរ៉ុប លើកទី ១៧ នៅរាជធានីភ្នំពេញ។

**ព្រឹត្តិការណ៍មួយ គួរកត់សម្គាល់ គឺ៖**

ដំណើរទស្សនកិច្ច របស់មន្ត្រីរាជការក្រសួងព័ត៌មាន និងអ្នកសារព័ត៌មាន សរុបជាង ២០០នាក់ ក្រោមការដឹកនាំរបស់**ឯកឧត្តម ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រី ក្រសួងព័ត៌មាន អញ្ជើញទៅកាន់បិណ្ឌនៅខេត្តត្រាវិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ( ខេត្តព្រះត្រពាំង កម្ពុជាក្រោម ) កាលពីថ្ងៃទី ៥-៦ ខែ កញ្ញា ឆ្នាំ ២០០៩ ដោយទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ដែលយើងមិននឹកស្មានដល់។ ដំណើរទស្សនកិច្ចកាន់បិណ្ឌ តាមប្រពៃណីព្រះពុទ្ធសាសនានេះ បានបង្កលក្ខណៈ និងឱកាសឱ្យមានការជួបប្រាស្រ័យទាក់ទង និងស្វែងយល់សុខទុក្ខពីគ្នា រវាងយើងជាពលរដ្ឋខ្មែរនៅ ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងព្រះសង្ឃ និងពុទ្ធបរិស័ទបងប្អូនរួមលោហិតនៃពូជពង្សខ្មែរ ដែលកំពុងរស់នៅឯនាយ ក្នុងប្រទេសវៀតណាម ហើយឆ្លងតាមអ្វីដែលយើងជួបប្រាស្រ័យដោយផ្ទាល់ និងមើលឃើញដោយប្រត្យក្សនឹងភ្នែកនេះ បានជម្រះអស់នូវ ភាពមន្ទិល ឬស្រពិចស្រពិលកន្លងមក រវាងបងប្អូនទាំងពីរ ។ ជាពិសេស ឆ្លងតាមដំណើរទស្សនកិច្ច ដ៏កម្រ មានរាប់ទសវត្សរ៍មកនេះ បានរួមចំណែកធ្វើឱ្យមានការយោគយល់គ្នាពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងសហប្រតិបត្តិ ការល្អ ដោយឈរលើគោលការណ៍គោរពអធិបតេយ្យភាព នៃប្រទេសទាំងពីរ កម្ពុជា និងវៀតណាម ។

បន្ទាប់ពីដំណើរទស្សនកិច្ច ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជាបន្តបន្ទាប់ស្ទើរគ្រប់ ស្ថានីយទូរទស្សន៍- វិទ្យុ ទស្សនាវដ្តី និងសារព័ត៌មាននានា បានធ្វើឱ្យប្រជារាស្ត្រខ្មែរយើងនៅក្នុងប្រទេស ក៏ដូចជាបងប្អូនខ្មែរ ដែលកំពុងរស់នៅក្រៅប្រទេស ទាំងមជ្ឈដ្ឋានមន្ត្រីរាជការតាមក្រសួង-ស្ថាប័ន ទាំងមជ្ឈដ្ឋានអ្នក នយោបាយមានការភ្ញាក់ផ្អើល រំភើប និងរំជួលចិត្តឥតឧបមា ហើយបានកោតសរសើរថា នេះជាព្រឹត្តិការណ៍ដ៏អស្ចារ្យ មួយក្រោមគំនិតផ្តួចផ្តើម ដ៏ឈ្លាសវៃ និងទំនាក់ទំនង ដ៏ប៉ិនប្រសប់របស់ **ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងព័ត៌មាន** ។

ចំណែកថ្នាក់ដឹកនាំ ជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បានបំពេញការងារយ៉ាងសកម្ម តាមការបែងចែកភារកិច្ច នៅក្នុងស្ថាប័ន ក្នុងការប្រជុំគណៈរដ្ឋមន្ត្រី -អន្តរក្រសួង និងការងារចំពោះកិច្ចនានារួមចំណែកជម្រុញឱ្យការងាររបស់ក្រសួងដំណើរការដោយរលូន និងទទួលបានលទ្ធផលគួរជាទីពេញចិត្ត ។

**២-<u>អគ្គនាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ</u>**

បានជំរុញយ៉ាងយកចិត្តទុកដាក់ក្នុងការចរាចរណ៍លិខិត **ចេញ-ចូល** ពីក្រសួងស្ថាប័ននានា និងអង្គភាពក្រោម ឱវាទ និងបានធ្វើកំណត់បង្ហាញជូនថ្នាក់ដឹកនាំ ពិនិត្យសំរេចតាមឋានានុក្រម
និងចាត់ការថតចម្លងបញ្ជូនទៅជូនថ្នាក់ដឹកនាំ ក្រសួង អង្គភាពចំណុះ និងមន្ត្រីពាក់ព័ន្ធបានជ្រាប និងអនុវត្តតាមសំណើរបស់ ក្រសួង-ស្ថាប័ន ចំណុះរាជរដ្ឋាភិបាល និងអង្គការនានា ។ បានតម្កល់ទុកឯកសារ បានត្រឹមត្រូវ និងធ្វើរបាយការណ៍បូកសរុបការងារជូនទីស្តីការ គណៈរដ្ឋមន្ត្រី ព្រឹទ្ធសភា រដ្ឋសភា បានទៀងទាត់តាមកាលវេលាកំណត់ ។

បានចេញប្រកាសដាក់មន្ត្រីរាជការ ឱ្យនៅក្រៅក្របខណ្ឌដើមចំនួន ០៨នាក់ ( ថ្នាក់ខេត្ត រាជធានី ០៧នាក់ ) ផ្ទេរក្របខណ្ឌមន្ត្រី រាជការ ចំនួន ០៣នាក់, ទទួលស្គាល់ក្របខណ្ឌ ដែលផ្ទេរមកពីក្រសួងសាធារណការ ចំនួន ០១នាក់, ប្រឡងជ្រើសរើសក្របខណ្ឌថ្មី ចំនួន ៧២នាក់ ស្រី ២៧នាក់ ( ថ្នាក់ឧត្តម ៣០នាក់, ថ្នាក់មធ្យម ២០នាក់, ថ្នាក់បឋម ២២នាក់ និងបានបញ្ចូលឈ្មោះក្នុងតារាងបៀវត្សរ៍ រួចរាល់ជាស្ថាពរ ) ។ បានដាក់មន្ត្រីរាជការឱ្យស្ថិតនៅភាពទំនេរ គ្មានប្រាក់បៀវត្សចំនួន ០៥នាក់ (នៅថ្នាក់កណ្តាល) បានបញ្ជូនប័ណ្ណព័ត៌មាន មន្ត្រីរាជការស៊ីវិលថ្នាក់កណ្តាល សម្រាប់រៀបចំអត្តសញ្ញាណប័ណ្ណថ្មី ចំនួន ១ ១៦៥នាក់ អវត្តមាន ២៧នាក់ (គ្មានមូលហេតុលុបឈ្មោះមន្ត្រី រាជការ ដោយសុំរបបគោលនយោបាយឧបត្ថម្ភម្តងគត់ ចំនួន ០៦នាក់) ។ បានតែងតាំងមន្ត្រីរាជការ ចំនួន ៦៩នាក់ (អនុប្រធាននាយកដ្ឋាន ១៧នាក់, ប្រធានការិយាល័យ ១១នាក់, អនុប្រធានការិយាល័យ ៤១នាក់) ស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ សម្រាប់ ឆ្នាំ ២០០៩ ចំនួន ២៨១គ្រឿង ។ បានបញ្ជូនមន្ត្រីរាជការចូលរៀនវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំ នៅសាលា ភូមិន្ទរដ្ឋបាល ចំនួន ០៥នាក់, មជ្ឈមណ្ឌល កម្ពុជា-សិង្ហបូរី ចំនួន ១៧នាក់ ចូលរួមសិក្ខាសាលាចំនួន ១៣នាក់, នៅសាធារណរដ្ឋប្រជាមានិតចិន

ចំនួន ០១នាក់ ។ បានតម្លើងឋានន្តរសក្តិ មន្ត្រីរាជការ ពីវរមន្ត្រី ទៅឧត្តមមន្ត្រី ចំនួន ០៩នាក់, ពីអនុមន្ត្រី ទៅវរមន្ត្រី ចំនួន ១៩នាក់, ។

ក្របខណ្ឌមន្ត្រីរាជការ សរុប ចំនួន ១.៩៥៨នាក់ (ក្នុងនោះមាន ស្រីចំនួន ៦១៥នាក់) ថ្នាក់កណ្តាល ១.១៩៧ នាក់ (ក្នុងនោះមានចំនួន ១.១៩៣នាក់ ស្រី ៣៩១នាក់ និងនៅថ្នាក់ រាជធានី ខេត្ត ចំនួន ៧៦១នាក់ (ក្នុងនោះមានស្រី ២២៣នាក់ ) ។

•ការងារ ចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋ ក្នុងឆ្នាំ ២០០៩ បានអនុវត្តដោយប្រក្រតី និងបានកែលំអពង្រីកគម្រោងផែនការថវិកាទូទៅ ឆ្នាំ ២០១០ ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់ ដែលកាន់តែកើនឡើង ។

•ការងារគ្រប់គ្រងសម្ភារៈ និងទ្រព្យរដ្ឋ ក្នុងឆ្នាំ ២០០៩ ត្រូវបានអនុវត្តស្របតាមគោលការណ៍ និងការសម្រេចដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ ក្នុងការគ្រប់គ្រង ចែកចាយ និងការជម្រះបញ្ជី ដើម្បីនិរន្តរភាពការងាររបស់អគ្គនាយកដ្ឋានចំណុះក្រសួង ក្នុងនោះមានការប្រគល់៖

-ម៉ាស៊ីនបោះពុម្ព ១គ្រឿង ម៉ាក KOMORI Spica 429-4ពណ៌ ជូនរោងពុម្ព

-សម្ភារៈបរិក្ខាបច្ចេកទេសទូរទស្សន៍ សម្រាប់ **ទទក**

-ជម្រះបញ្ជីសារពើភ័ណ្ឌសម្ភារៈ បរិក្ខា របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា

-បានរៀបចំកំណត់ទីតាំង និងកំណត់ថ្លៃបណ្តោះអាសន្ន ផ្ទៃដី និងអារគារទីស្តីការក្រសួង និងអង្គភាពចំណុះនៅថ្នាក់កណ្តាលរួចរាល់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច មុននឹងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានរៀបចំកែលំអប្រព័ន្ធទឹក-ភ្លើង ក្នុងបរិវេណអាគារទីស្តីការក្រសួង

•**នាយកដ្ឋានសវនកម្មផ្ទៃក្នុង** គឺជាអង្គភាពមួយចំណុះផ្ទាល់ឯកឧត្តមរដ្ឋមន្ត្រី មានភារកិច្ចអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង និងវាយតម្លៃអង្គភាពចំណុះក្រសួង ដើម្បីធានានូវប្រសិទ្ធភាពនៃប្រតិបត្តិការរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចទុកចិត្តបានស្របតាមច្បាប់ និងបទប្បញ្ញត្តិនានាទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ។

ក្នុងឆ្នាំ ២០០៩ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើប្រតិបត្តិការ ការងារបច្ចេកទេស ការងាររដ្ឋបាល ការងារបុគ្គលិក និងបណ្តុះបណ្តាល និងការងារទំនាក់ទំនងជាមួយស្ថាប័ននានា ទន្ទឹមនេះ ក៏បានបញ្ជូនមន្ត្រីមួយចំនួន ចូលរួមក្នុង កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរ សវនកម្មជាតិ និងអង្គការស្ថាប័នដៃគូមួយចំនួន ក្នុងគោលដៅលើកកម្ពស់សមត្ថភាព ក្នុងការអនុវត្ត ភារកិច្ចរបស់ខ្លួន ។

•**<u>កិច្ចសហប្រតិបត្តិការ និងការងារអាស៊ាន :</u>**

ក្នុងឆ្នាំ ២០០៩ កន្លងទៅនេះ ការិយាល័យអាស៊ាន បានយកចិត្តទុកដាក់បំពេញការងាររបស់ខ្លួនយ៉ាងសកម្ម ទាំងក្នុងប្រទេស និងក្រៅប្រទេស ដូចខាងក្រោមនេះ ៖

-បានរៀបបែបបទចំជូន ឯកឧត្តមរដ្ឋមន្ត្រី ទៅចូលរួមសន្និសីទ ព័ត៌មានអាស៊ី លើកទី ៦ -ទៅធ្វើទស្សនកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងបានរៀបចំទទួលអនុរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងសារគមនាគមន៍វៀតណាម អញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា ។

-ជាពិសេសបន្ទាប់ពីទស្សនកិច្ច របស់គណៈប្រតិភូក្រសួងព័ត៌មាន និងសារគមនាគមន៍វៀតណាមនៅកម្ពុជា នៅខែ វិច្ឆិកា ឆ្នាំ ២០០៩ កិច្ចព្រមព្រៀងមួយរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៩ នៅខេត្ត ព្រះសីហនុ ។ យោងតាម កិច្ចព្រមព្រៀងនេះ ភាគីវៀតណាមបានសន្យា ជួយបណ្តុះបណ្តាលរយៈពេលវែង និងខ្លីលើវិស័យផ្សព្វផ្សាយព័ត៌មាន សម្រាប់វិទ្យុ និងទូរទស្សន៍ ដល់មន្ត្រីកម្ពុជា និងបានព្រមផ្តល់ឱ្យ ក្រសួងព័ត៌មាន នូវ វិទ្យុ FM កម្លាំង ២ KW ចំនួន ០៥គ្រឿង និងវិទ្យុ FM ៥ KW ចំនួន

០១គ្រឿង សម្រាប់តម្លើងនៅតាមខេត្តនៅកម្ពុជា ។ នេះជាជំនួយ ឥតសំណងរបស់ សាធារណរដ្ឋសង្គមនិយមវៀតណាម ជូនក្រសួងព័ត៌មាន ។

-បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពី ASEAN NEWS MAKERជូនដល់ គ្រូនិងសិស្សចំនួន ៤០នាក់ និងបើកវគ្គបណ្តុះបណ្តាល ស្ត្រី ជាអ្នកសារព័ត៌មាន វិទ្យុ និងទូរទស្សន៍ចំនួន ១៣នាក់ ។

-បានរៀបចំបញ្ជូន ទីប្រឹក្សាក្រសួង មន្ត្រីរបស់វិទ្យុជាតិ ទូរទស្សន៍ជាតិ ព័ត៌មាន និងសោតទស្សន៍ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP គណៈកម្មការអាស៊ាន អ្នកសារព័ត៌មានរដ្ឋនិងឯកជន ចំនួនសរុប ៤៣នាក់ ទៅចូលរួមប្រជុំ ចូលរួមសិក្ខាសាលា ទៅធ្វើទស្សនកិច្ចដកពិសោធន៍ តាមជំនាញរៀងៗខ្លួន នៅតាមប្រទេសមួយចំនួនដូចជា ៖ ជប៉ុន ឥណ្ឌា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតចិន ថៃ ហ្វីលីពីន សឹង្ហបុរី បែលហ្ស៊ិក និងក្រុងម៉ាកាវ ប្រទេសចិន ។

**៣-<u>អគ្គនាយកដ្ឋាន ព័ត៌មាន និងសោតទស្សន៍</u>**

បានដំណើរការការងារជាប្រក្រតី ដោយបានធ្វើការសំរបសំរួលលិខិតស្នាមផ្សេងៗជូនអ្នកសារព័ត៌មានក្នុងការចុះបំពេញការងារតាមមូលដ្ឋាននិងជូនព័ត៌មានអំពីកម្មវិធីនានាតាមរយៈទូរស័ព្ទ ព្រមទាំងបានចាត់មន្ត្រីចុះយកព័ត៌មានតាមក្រសួងមន្ទីរនានាដោយផ្ទាល់ទៀតផង ។ ព្រមជាមួយនេះ ក៏បានអនុញ្ញាតឱ្យអង្គការសារព័ត៌មានដំណើរការបោះពុម្ពផ្សាយ បន្តអាជ្ញាប័ណ្ណ ប្តូរឈ្មោះសារព័ត៌មាន និងធ្វើការផ្អាកការចេញផ្សាយរបស់សារព័ត៌មាន ដែលផ្ទុយនឹង ច្បាប់ និងក្រមសីលធម៌ ។ ទន្ទឹមនឹងនេះ ក៏នៅបានធ្វើការតាមដានជាប្រចាំរាល់ព័ត៌មាន ដែលចេញផ្សាយតាមទំព័រ សារព័ត៌មាន វិទ្យុ-ទូរទស្សន៍ និងតាមដានការវិវាទនានា របស់អ្នកសារព័ត៌មាន ព្រមទាំងធ្វើការបញ្ជូនមន្ត្រីចូលរួមវគ្គ ជំនាញផ្សេងៗ និងបញ្ចូលព័ត៌មានទៅក្នុងគេហទំព័រ របស់ក្រសួងថែមទៀត ។

**<u>ការងារជាក់ស្តែង</u> ៖**

-ផ្តល់ព័ត៌មានជូនអង្គភាពសារព័ត៌មាន ឱ្យចូលរួមយកព័ត៌មានអំពីព្រឹត្តិការណ៍សំខាន់ៗ ចំនួន ១០៩លើក និងបញ្ជូនព័ត៌មានផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាលដល់សារព័ត៌មានជាតិ និងអន្តរជាតិ បានចំនួន ៤០៣ដំណឹង បញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា និងប្រជុំអន្តរក្រសួង ចំនួន ៤លើក និងតាមការស្នើសុំរបស់ក្រុមហ៊ុន នានា ចំនួន ២៥លើក ព្រមទាំងបានបញ្ចូលព័ត៌មានក្នុងគេហទំព័របានចំនួន ៧១ អត្ថបទ ។

**<u>អនុញ្ញាតឱ្យ</u>** កាសែតជាតិបោះពុម្ពផ្សាយថ្មីចំនួន ១៦ បន្តសុពលភាព ១៦២ ប្តូរឈ្មោះ ២ ផ្ទេរសិទ្ធិ ១ -ព្រឹត្តបត្រ បោះពុម្ពផ្សាយថ្មីចំនួន ០៨ បន្តសុពលភាព ០៣ ផ្ទេរសិទ្ធិ ០១ -ទស្សនាវដ្តីជាតិបោះពុម្ពផ្សាយថ្មីចំនួន ១៦ បន្តសុពលភាព ២៦ ប្តូរឈ្មោះ ០៣ ផ្ទេរសិទ្ធិ ១០ -កាសែតបរទេសបោះពុម្ពផ្សាយថ្មីចំនួន ០៣ បន្តសុពលភាព ០២ -ទស្សនាវដ្តីបរទេស បោះពុម្ពផ្សាយថ្មីចំនួន ១០ បន្តសុពលភាព ០៤ -សារព័ត៌មាននាំចូលចែកផ្សាយចំនួន ០១ -សមាគមអ្នកសារព័ត៌មាន បើកថ្មីចំនួន ០២ -រោងពុម្ពបើកថ្មីចំនួន ០៥ បន្តសុពលភាព ៣៧ -គ្រឹះស្ថានបោះពុម្ពផ្សាយបើកថ្មី ០១ ។

តាមទិន្នន័យសរុបឆ្នាំ ២០០៩នេះ មានកាសែតជាតិចំនួន ៣៨៥ ព្រឹត្តបត្រចំនួន ៥០ ទស្សនាវដ្តីជាតិចំនួន ១៧២ កាសែតបរទេសចំនួន ៣៤ទស្សនាវដ្តីបរទេសចំនួន ២៨ សារព័ត៌មាននាំចូលចំនួន ១០ ទីភ្នាក់ងារសារព័ត៌មាន អន្តរជាតិ ចំនួន ១១ សមាគមអ្នកសារព័ត៌មានចំនួន ២១ រោងពុម្ពចំនួន ១៣៣ គ្រឹះស្ថានបោះពុម្ព ចំនួន ០៦ ។

-ស្ថានីយ **វិទ្យុផ្សាយ នៅភ្នំពេញ** មានចំនួន ៣១ នៅតាមបណ្តាខេត្ត ៣៨ សរុប ៦៩ ស្ថានីយ

-ស្ថានីយ **វិទ្យុ ផ្សាយបន្ត នៅភ្នំពេញ** មានចំនួន ០៣ នៅតាមបណ្តាខេត្ត ២៥ សរុប ២៨ ស្ថានីយ

-ស្ថានីយ **ទូរទស្សន៍ នៅភ្នំពេញ** មានចំនួន ០៩ នៅតាមបណ្តាខេត្ត ០៧ សរុប ១៦ ស្ថានីយ

-ស្ថានីយ **ទូរទស្សន៍ ផ្សាយបន្ត នៅភ្នំពេញ** មានចំនួន ០២ នៅតាមបណ្តាខេត្ត ៣៦ សរុប ៣៨ ស្ថានីយ

-**ទូរទស្សន៍ខ្សែកាប** នៅភ្នំពេញមានចំនួន ០៣ តាមបណ្តាខេត្ត ១០២ សរុប ១០៥ ស្ថានីយ

-ក្រៅពីនេះ មានសមាគម ទូរទស្សន៍ ០១ និងសមាគម វិទ្យុ ០១ ផងដែរ ។

-បានសហការរៀបចំពិធីសំណេះសំណាល ជួបជាមួយអង្គភាពទស្សនាវដ្ដី ០១លើក -ប្រជុំគណៈកម្មការគ្រប់គ្រងការផ្សាយភាសាចាម ០១លើក -សហការរៀបចំ Media center សម្រាប់កិច្ចប្រជុំ ASEAN-EU លើកទី ១៧-ប្រជុំគណៈកម្មការគ្រប់គ្រងការផ្សាយ អាហ្វីសប៉ាណូ ស្លាកសញ្ញា ប័ណ្ណប្រកាស និងធ្វើការសិក្សាលើនីតិវិធីជួបប្រជុំ ០១លើក -បានរៀបចំប្រជុំសំណេះសំណាល និងបំប៉នអ្នកនិពន្ធ អ្នកដឹកនាំរឿង អ្នកបញ្ចូលសម្លេង ពិធីករ ពិធីការិនីតាមបណ្ដាស្ថានីយវិទ្យុ និងទូរទស្សន៍ ០១លើក និងបើកវគ្គបណ្ដុះបណ្ដាលបច្ចេកទេសភាពយន្ត ០១លើក -បានចុះណែនាំដល់អ្នកសារព័ត៌មាននៅខេត្តសៀមរាប០១លើក ។

II-**<u>អំពីការងារផ្សព្វផ្សាយ</u>** :

ដើរទន្ទឹមនឹងការពង្រីកបណ្ដាញផ្សព្វផ្សាយ និងបើកទូលាយវិស័យបច្ចេកវិទ្យាព័ត៌មាន ទាំងរបស់រដ្ឋនៅថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ និងការចូលរួមពីបណ្ដាញផ្សព្វផ្សាយឯកជន យើងបានកត់សម្គាល់នូវការរីកចម្រើនផ្នែកមធ្យោបាយទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ ក៏កាន់តែកើនឡើងដែរ។ តាមស្ថិតិជំរឿន ទូទៅនូវប្រជាសាស្ត្រឆ្នាំ ២០០៨ ដែលក្រសួងផែនការ បានប្រកាសផ្សព្វផ្សាយកាលពីខែ កញ្ញា ឆ្នាំ ២០០៩ បានឱ្យដឹងថា ប្រជាជនទាំងពីរភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ២០០៨ មានចំនួន ១៣,៤លាននាក់ រួមមាន ២,៨ លានគ្រួសារក្នុងនោះមាន ១ ៦៤៥ ៨៩១ គ្រួសារ( ស្មើ ៥៨,៤១% នៃគ្រួសារសរុប ) មានទូរទស្សន៍ និង ១ ១៤៩ ៨០៧គ្រួសារ (ស្មើ ៤០,៨១% នៃគ្រួសារសរុប) មានវិទ្យុម៉ាញ៉េ សម្រាប់ទទួលព័ត៌មាន ការកម្សាន្ត និងការអប់រំផ្សេងៗពីគ្រប់បណ្ដាញផ្សព្វផ្សាយទាំងទូរទស្សន៍ វិទ្យុ និងសារព័ត៌មានបោះពុម្ព។ ទន្ទឹមនេះ ប្រជាជនក៏មានមធ្យោបាយរថយន្តតូច-ធំ ចំនួនជាង ១៣ម៉ឺនគ្រឿង ដែលក្នុងនោះ ក៏មានបំពាក់ដោយវិទ្យុ ទទួលសំឡេងផងដែរ ។

ក្នុងរយៈពេលមួយឆ្នាំនេះ ប្រព័ន្ធផ្សព្វផ្សាយជាតិបានយកចិត្តទុកដាក់ផ្សព្វផ្សាយពីព្រះរាជសកម្មភាព ព្រះមហាក្សត្រ សកម្មភាពថ្នាក់ដឹកនាំ ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល សម័យប្រជុំរដ្ឋសភា ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអំពីគ្រប់ស្ថាប័នជាតិ អំពីដំណើរការជំរះក្ដី របស់សាលាក្ដីកាត់ទោសមេដឹកនាំខ្មែរក្រហម។ល។ និយាយរួម ប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិបានធានាវ៉ាប់រងបានយ៉ាងពេញលេញ ទូលំទូលាយ ទាន់ពេលវេលា និង ប្រកបដោយគុណភាពខ្ពស់ ទាំងបច្ចេកទេស និងខ្លឹមសារ ក្នុងការផ្សព្វផ្សាយអំពីព្រឹត្តិការណ៍ ជាតិ អន្តរជាតិ កម្មវិធីអប់រំលើគ្រប់វិស័យ និងកម្មវិធីកម្សាន្ត ជូនដល់ប្រជាជនខ្មែរ ទាំងក្នុង និងក្រៅប្រទេស ។

ទន្ទឹមនេះ ការពង្រីកអនុភាព និងវិសាលភាព នៃការផ្សព្វផ្សាយ ( បណ្ដាញទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន ) ទៅកាន់ឯនាយជើងមេឃ នៃមាតុប្រទេស ក៏បានរួមចំណែកធ្វើឱ្យពិភពលោកបានឃើញ បានស្គាល់អំពីអត្ថិភាព និងអត្តសញ្ញាណ ជាតិខ្មែរ ដែលជាការលើកកម្ពស់កិត្យានុភាព របស់ព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ។ ជាពិសេសប្រជារាស្ត្រខ្មែរបាន ទទួលព័ត៌មានកាន់តែទូលំទូលាយ មានតុល្យភាព និងមានការយល់ដឹងកាន់តែប្រសើរឡើងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនជា ពលរដ្ឋខ្មែរ ក្នុងការសម្រេចចិត្តដ៏ត្រឹមត្រូវ ដើម្បីចូលរួមអភិវឌ្ឍក្នុងគ្រប់វិស័យនៃសង្គមកិច្ច ។

## ១~ <u>អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា</u>

បានដំណើរការផ្សព្វផ្សាយរៀងរាល់ថ្ងៃ តាមប្រព័ន្ធ AM 918 KHz និង FM ជាតិ 96 MHz និងវិទ្យុវត្តភ្នំ 105,75 MHz ដែលត្រូវបានធ្វើការផ្សាយនូវ កម្មវិធី ព័ត៌មាន កម្មវិធីអប់រំ កម្មវិធីកម្សាន្ត ជូនសាធារណជនគ្រប់មជ្ឈដ្ឋាន ។ ទន្ទឹមនេះ វិទ្យុជាតិកម្ពុជាបានផលិតកម្មវិធីថ្មីៗ ប្លែកៗជាច្រើន ផ្សព្វផ្សាយបន្ថែមទៀតដើម្បីធ្វើឱ្យការផ្សាយ ទទួលបានការគាំទ្រពីមិត្តអ្នក ស្ដាប់ទាំងក្នុង និងក្រៅប្រទេស។ ជាពិសេស វិទ្យុជាតិកម្ពុជាបានវ៉ាប់រង ផ្សាយបន្តផ្ទាល់នូវគ្រប់ពិធីបុណ្យជាតិ និងបុណ្យ ប្រពៃណីជាតិសំខាន់ៗ បានទាន់ពេលវេលាឆ្លើយតបបានយ៉ាងរស់រវើក នូវការជក់ចិត្តតាមដានស្ដាប់ របស់ប្រជាពលរដ្ឋ ។

ចំពោះកម្មវិធីព័ត៌មានក្នុងនិងក្រៅប្រទេស វិទ្យុជាតិបានធ្វើការចុះយកព័ត៌មានដោយផ្ទាល់ និងផ្តល់ដោយមន្ទីរព័ត៌មាន រាជធានី-ខេត្ត ការដកស្រង់ពីអត្ថបទកាសែត ទស្សនាវដ្តី និង វិទ្យុបរទេស ព្រមទាំងបានធ្វើការផ្សាយព័ត៌មានរាយការណ៍តាម ទូរស័ព្ទ ដែលកំពុងពេញនិយមទៀតផង ។ ក្រៅពីការផ្សាយជាភាសាជាតិ វិទ្យុជាតិក៏នៅបានផ្សាយជា ភាសាបារាំង អង់គ្លេស ដែលក្នុងនោះ វិទ្យុ AM ផ្សាយ ១០នាទី ក្នុង១ថ្ងៃ ពីថ្ងៃច័ន្ទ ដល់ថ្ងៃ សុក្រ រីឯវិទ្យុ FM ផ្សាយភាសាអង់គ្លេស១០នាទី ក្នុងមួយថ្ងៃ, ភាសាចិន ៨នាទី ក្នុងមួយថ្ងៃ, ភាសាវៀតណាម ៨នាទី ក្នុងមួយថ្ងៃ ។ ព្រមជាមួយនេះ វិទ្យុ AM បានសហការផលិតកម្មវិធី សន្ទនាមតិ "**អ្នកក៏មានឱកាស**" និងសហការជាមួយវិទ្យុអូស្ត្រាលី ABC ផ្សព្វផ្សាយពីកម្មវិធី " **ជីវិតយើង សង្គមយើង** " ដោយលើកឡើងនូវប្រធានបទថ្មីៗ ច្រើនទៀតស្របតាមសភាពការណ៍ប្រទេសជាតិ ។

វិទ្យុជាតិកម្ពុជា AM 918 KHz FM 105,75 MHZ បានធ្វើការផ្សព្វផ្សាយជារៀងរាល់ថ្ងៃម៉ោង ០៥:៣០ ដល់ ម៉ោង ២៣:00 ។ រយៈពេលមួយ ឆ្នាំនេះ ផ្សាយបាន ៦,៣៨៧ ម៉ោងរួមមាន : ព័ត៌មានក្នុងប្រទេសចំនួន ១០ ០៥0អត្ថបទ ព័ត៌មានរាយការណ៍តាមទូរស័ព្ទ ១៨០ អត្ថបទ ព័ត៌មានអន្តរជាតិ ៧ ៣៧០ អត្ថបទ និងនាទី ផ្សេងៗ ៨២៣ អត្ថបទ និងកម្មវិធីកម្សាន្ត មានសិល្បៈសម័យ (ចម្រៀងពេលព្រឹក វិថីយុវវ័យ យល់ដឹងសកល **សម្រស់ភូមិខ្ញុំ ជីវិតនិងការងារ រីករាយពេលសាយ័ណ្ហ** ចម្រៀងល្បីៗ កម្សាន្តពេលរាត្រី ជជែកកម្សាន្ត បានចំនួន ៣ ៣០៦ កម្មវិធី សិល្បៈបុរាណ(អាយ៉ៃឆ្លើយឆ្លង ៣៥ខ្សែ ចាប៉ីឆ្លើយឆ្លង ២៦ខ្សែ ចាប៉ីរឿង ១៤រឿង យីកេរឿងចំនួន ១៥រឿង ល្ខោនបាសាក់ ០៥រឿង) សោភ័ណថ្ងៃអាទិត្យ ៤៤ កម្មវិធី ស្រាវជ្រាវ ប្រពៃណី-វប្បធម៌ខ្មែរ ៤៦ កម្មវិធី ជួបមិត្តសិល្បករ ៣៦កម្មវិធី ព្រះពុទ្ធសាសនា ៤០កម្មវិធី ចេញរថយន្តថត និងបំពងសំឡេង តាមពិធីនានា ជាផ្លូវការរដ្ឋ ២៤៦ ដង អស់ ២៨១បង់) ។

វិទ្យុជាតិ FM ជាតិ 96 MHz បានធ្វើការផ្សព្វផ្សាយពីម៉ោង ០៥:៣០ ដល់ម៉ោង ២៤:00 ដោយបានផ្សាយព័ត៌មានក្នុងប្រទេស ចំនួន ២ ៣១២ អត្ថបទ ព័ត៌មានអន្តរជាតិ ២ ១៩៧ អត្ថបទ ព័ត៌មានរាយការណ៍តាមទូរស័ព្ទ ១៨៤ លើក សេចក្តីរាយការណ៍ ដោយសូរស័ព្ទ ៣៥៥អត្ថបទ ។ ផ្សាយព័ត៌មានជាភាសា អង់គ្លេស បាន ១៥៣១ អត្ថបទ ភាសាចិន ១ ៦៣២ អត្ថបទ ភាសាវៀតណាម ១ ៤៦៤ អត្ថបទ និងផ្សាយកម្មវិធីទូទៅជាច្រើនរុំលទៀត ដោយកម្មវិធីនីមួយៗ ពិធីករបានធ្វើបទបង្ហាញនូវអត្ថបទគ្រប់ប្រភេទ ដើម្បីផ្តល់នូវចំណេះដឹងដល់មិត្ត អ្នកស្តាប់ដូចជា :ព្រះធម៌អភិធម្ម និង សន្ទនាធម៌ ៧៣៤ វគ្គ និងបានធ្វើការសន្ទនា ឆ្លើយឆ្លងជាមួយអ្នកស្តាប់តាមទូរស័ព្ទ ដើម្បីបង្កើតបរិយាកាសសប្បាយរីករាយដល់យុវវ័យទៀតផង ក្នុងនោះមាន អត្ថបទ និង នាទីផ្សេងៗ ៣.៩៤៦ អត្ថបទ ទទួលសំណេះសំណាលតាមទូរស័ព្ទ ១០ ៦៧០ លើក ។

-<u>**ការងារសហប្រតិបត្តិការ**</u> :

ដោយបានឯកភាព ដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រី ក្រសួងព័ត៌មាន វិទ្យុជាតិកម្ពុជាបានធ្វើការទាក់ទង សហប្រតិបត្តិការប្រកបដោយផ្លែផ្កាយ៉ាងល្អ ជាមួយវិទ្យុសំឡេងប្រជាជនវៀតណាម VOV-វិទ្យុផ្សាយសំឡេងប្រជាជនខេត្ត ក្វាងស៊ី-វិទ្យុជាតិអន្តរជាតិចិន នៃសាធារណរដ្ឋប្រជាមានិតចិន -វិទ្យុ ABC អូស្ត្រាលី និង អង្គការ BBC WST ។

## ២- <u>អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា</u>

ឆ្នាំ ២០០៩ គឺជាឆ្នាំដែលទូរទស្សន៍ជាតិកម្ពុជាឈានដល់ដំណាក់កាលប្រមើលឃើញការប្រឈម នឹងស្ថានភាពប្រកួតប្រជែងជាបណ្តើរៗ ក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយទំនើប និងពេញនិយមនៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ គឺក្នុងចក្ខុវិស័យនេះហើយ ដែលជម្រុញឱ្យមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានទូរទស្សន៍ ជាតិកម្ពុជាបានយកចិត្តទុកដាក់រក្សាតួនាទីឈានមុខ ជាអង្គភាពផ្សព្វផ្សាយរបស់រដ្ឋ ក្នុងការផលិត និងផ្សព្វផ្សាយយ៉ាងសកម្ម ទាំងរូបភាព ខ្លឹមសារនូវព្រឹត្តិការណ៍ថ្មីៗនិងការអភិវឌ្ឍន៍ ប្រទេសជាតិលើគ្រប់វិស័យ ។ ជាក់ស្តែងទូរទស្សន៍ជាតិកម្ពុជា បានផ្សព្វផ្សាយ

យ៉ាងទូលំទូលាយ នូវព័ត៌មានជាច្រើនទាក់ទងដល់ ព្រះរាជសកម្មភាព របស់ព្រះមហាក្សត្រ សកម្មភាព សម្តេចប្រធានព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ ស្ថាប័ន មន្ទីរ ខេត្ត ក្រុង និងសកម្មភាព ការងាររបស់ប្រជាពលរដ្ឋទូទាំងប្រទេស ក្នុងនោះមានវិស័យនយោបាយ យោធា សន្តិសុខ សេដ្ឋកិច្ច វប្បធម៌ សុខាភិបាល កាកបាទក្រហម ពាណិជ្ជកម្ម កសិកម្ម អប់រំ និងកីឡា ព្រមទាំងទំនាក់ទំនងអន្តរជាតិ ។ល។ ជាពិសេសគោលនយោបាយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដែលមាន **សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន** ជាប្រមុខដឹកនាំ ដ៏ឈ្លាសវៃ ។

ទូរទស្សន៍ជាតិកម្ពុជា បានដំណើរការផ្សាយរៀងរាល់ថ្ងៃ ទាំងនៅក្នុងប្រទេស និងចេញទៅក្រៅប្រទេស ។ នៅក្នុងប្រទេស ផ្សាយបីពេល ក្នុងមួយថ្ងៃ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ព្រឹកពីម៉ោង ០៦:០០ ដល់ម៉ោង ០៨:៣០ថ្ងៃត្រង់ ពីម៉ោង ១១:៣០ ដល់ម៉ោង ១៤:៣០, ល្ងាចពីម៉ោង ១៧:០០ ដល់ម៉ោង ២៣:០០។ ដោយឡែកថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ចាប់ផ្សាយពីម៉ោង ៦:០០ ដល់ម៉ោង ២៣:០០ និងផ្សាយទៅក្រៅប្រទេសពីម៉ោង ០១:០០ ដល់ម៉ោង ០៥:០០ ។

ទូរទស្សន៍បានផលិត និងផ្សាយកម្មវិធីជាច្រើនជូនទូរទស្សនិកជនគ្រប់មជ្ឈដ្ឋាន មានកម្មវិធីព័ត៌មានក្នុង ប្រទេស ព័ត៌មានអន្តរជាតិ ( ដកស្រង់ពីទូរទស្សន៍បារាំង CFI ចិន CCTV9 ជប៉ុន NHK និង AP ) កម្មវិធីអប់រំ កម្មវិធីកម្សាន្ត និងកម្មវិធីផ្សេងៗទៀត ដូចជា “កម្មវិធីអរុណសួស្តីកម្ពុជា” “ការងារពិត” “លិខិតផ្ញើជូនអ្នកមានគុណ” “សៀវភៅល្អៗ” “ទីក្រុងល្អ ចរាចរណ៍មានសុវត្ថិភាព” “នាទីបរិស្ថាននិងសោភ័ណភាពទីក្រុង” “កម្មវិធីសមធម៌ប្រចាំសប្តាហ៍” “តន្ត្រីអន្តរជាតិប្រចាំថ្ងៃអាទិត្យ” និងផ្សាយព័ត៌មានភាសាបារាំង TVK en français, ភាសាអង់គ្លេស TVK today ព្រមទាំងបញ្ចូលព័ត៌មាន ជាភាសាអង់គ្លេស ទៅក្នុងគេហទំព័រ របស់ខ្លួនទៀតផង...។ល។

រយៈពេលមួយឆ្នាំនេះ **ទទក** បានផ្សាយនៅក្នុងប្រទេសមានរយៈពេល ៥ ១៣១ ម៉ោង រួមមាន: ព័ត៌មានហ្វីល ៣៩៥០ អត្ថបទ ព័ត៌មានអាន ៧៤៨ អត្ថបទ ព័ត៌មានអន្តរជាតិ ២ ៧៦៩ អត្ថបទ ព័ត៌មានពីព្រះបរមរាជវាំង ២០៥អត្ថបទ ព័ត៌មានសហគមន៍ ជាតិ ៣ ០៦៧ អត្ថបទ ព័ត៌មានខេត្ត ២ ៣៨១អត្ថបទព្រះរាជឱង្ការដើម ១៥ដង សំឡេងដើម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ចំនួន ១២ដង **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ចំនួន ៧៩ដង ផ្សាយទាំងស្រុងសម័យប្រជុំព្រឹទ្ធសភា ០៩ថ្ងៃ រដ្ឋសភា ៣៨ថ្ងៃ ផ្សាយផ្ទាល់ចំនួន ១៧ដង រួមមាន(ខួបលើកទី៣០ ថ្ងៃជ័យជំនះ ៧មករា នៅពហុកីឡដ្ឋានអូឡាំពិច កិច្ចប្រជុំរដ្ឋមន្ត្រី ការបរទេស អាស៊ាន សហភាពអ៊ឺរ៉ុប,ព្រះពិធីច្រត់ព្រះនង្គ័ល,ព្រះពិធីបុណ្យអុំទូក លយប្រទីប អកអំបុក សំពះព្រះខែ.បុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា, សាលាក្តីកាត់ទោសកាំង ហ្គេចអ៊ាវ,សម្តេចតេជោ និងលោកជំទាវ ចូលរួមទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។ ផ្សាយទៅក្រៅប្រទេសរយៈពេល ១០៨៤ម៉ោង រួមមាន ព័ត៌មានភាសាជាតិ ២០នាទី x ៣៦៥ថ្ងៃ ភាសាបារាំង ៣០នាទី x ៤៨ថ្ងៃ ភាសាអង់គ្លេស ១០នាទីx២៤០ថ្ងៃ ។

បានផ្សាយកម្មវិធីនាទីអប់រំ : បទយកការណ៍ ៣៥៥អត្ថបទឯកសារ ១៧២អត្ថបទ នាទីវប្បធម៌ ៤៨អត្ថបទ សុខភាព ៥៨អត្ថបទ បរិស្ថាន ៤៧អត្ថបទ អប់រំ ៤៨អត្ថបទ ។

បានផ្សាយកម្មវិធីនាទីកម្សាន្ត : បីបាច់ដោយទន្លេតែមួយ ៥២ វគ្គ សមធម៌ ២៣វគ្គ **ខ្ញុំ និង អ្នក** ៤៧វគ្គ **កូនឆ្លាត** ៣៤វគ្គ ល្ខោនបាសាក់ ៤៨វគ្គ ល្ខោននិយាយ ១២វគ្គ វីដេអូស្រ្តីកម្ពុជា ៤៨ វគ្គ យល់ដឹងពីអាស៊ាន ១១វគ្គ បរិស្ថាន ៥០វគ្គ , លើកកម្ពស់ពីសីលធម៌សង្គម ០៤វគ្គ ។

ជារួមក្នុងឆ្នាំ ២០០៩ ទូរទស្សន៍ ជាតិកម្ពុជានៅតែបំពេញតួនាទីឈានមុខ ជាអង្គភាព ផ្សព្វផ្សាយរបស់រដ្ឋក្នុងការបំពេញសេវាផ្តល់ព័ត៌មានផ្លូវការ ច្បាស់ការនូវព្រឹត្តិការណ៍ជាតិ អន្តរជាតិ ដែលឆ្លុះបញ្ចាំងអំពីគ្រប់ទិដ្ឋភាពសង្គម ទាំងនយោបាយ សេដ្ឋកិច្ច វប្បធម៌ ។ល។ ជូនដល់ប្រជារាស្ត្រខ្មែរទាំងក្នុង និងក្រៅប្រទេស ។ **ទទក** ក៏ធានាបានការផ្សាយបន្តផ្ទាល់អំពីព្រឹត្តិការណ៍ សំខាន់ៗដូចជាពិធីបុណ្យជាតិ បុណ្យប្រពៃណីជាតិ និង ព្រះរាជសកម្មភាពព្រះមហាក្សត្រ និងសកម្មភាពរបស់ថ្នាក់ដឹកនាំ គ្រប់ស្ថាប័នជាតិ និងភ្ញៀវជាន់ខ្ពស់ នៃបណ្តាប្រទេសជាមិត្ត ។ រាល់កម្មវិធីអប់រំច្បាប់ និងសង្គម និងកម្មវិធីកំសាន្តរបស់ **ទទក** ជានិច្ចជាកាលរក្សាបាននូវគុណធម៌ និងសីលនិច្ច័យខ្ពស់

គឺក្នុងសម្បជញ្ញៈដឹងខុសត្រូវ អំពីសីលធម៌សង្គម រួមចំណែករក្សាបាននូវ ទំនៀមទម្លាប់វប្បធម៌ប្រពៃណីល្អរបស់ជាតិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សខ្មែរ និងសង្គមខ្មែរ ។

## ៣- <u>**អគ្គនាយកដ្ឋាន ទីភ្នាក់ងារសារព័ត៌មានកម្ពុជា** AKP</u>

បានដំណើរការការងារជាប្រក្រតី ក្នុងការចុះយកព័ត៌មាន ថតរូបតាមបណ្តាស្ថាប័ន ក្រសួង មន្ទីរ ខេត្ត រាជធានី ជិតឆ្ងាយ ក្នុងព្រះរាជាណាចក្រកម្ពុជា និងដកស្រង់ព័ត៌មានអន្តរជាតិតាមប្រព័ន្ធអេឡិកត្រូនិក ជាភាសាបារាំង និងអង់គ្លេស ពីទីភ្នាក់ងារ XINHUA និង VNA មកធ្វើការផ្សព្វផ្សាយរៀងរាល់ថ្ងៃជាភាសាជាតិ តាមរយៈព្រឹត្តបត្រប្រចាំថ្ងៃ ផ្សាយព័ត៌មានជា ភាសាខ្មែរ បារាំង អង់គ្លេស និងថតរូបជាភាសាអង់គ្លេស តាមប្រព័ន្ធអេឡិកត្រូនិក ព្រមទាំងបានបោះពុម្ពផ្សាយជាទស្សនាវដ្តី ប្រចាំខែ (KAMBUJA) និងសារព័ត៌មានថតរូប “Affiche” ទៀតផង ។

រយៈពេលមួយឆ្នាំនេះ ចុះយកព័ត៌មានបាន ៣ ១២៣ លើក និពន្ធបាន ២ ៩៥៦ ដំណឹង ក្នុងនោះមានដំណឹង AKP រាជធានី-ខេត្ត ៦៣០ ដំណឹង រូបថត ៣ ១៤៣ រូប បកប្រែព័ត៌មានក្រៅប្រទេសបាន ២ ២៦៥ ដំណឹង ។ បញ្ជូនព័ត៌មានតាមប្រព័ន្ធអេឡិកត្រូនិក ទៅស្ថានទូតខ្មែរក្រៅប្រទេស ចំនួន២៤ ទីភ្នាក់ងារ VNA នៅហាណូយ និងភ្នំពេញ Radio Press ជប៉ុន ស្ថានទូតអាមេរិក នៅបាងកក ទីភ្នាក់ងារគុយបា Prensalatina នៅហាណូយ ស្ថានទូត គុយបានៅភ្នំពេញ ទីភ្នាក់ងារ XINHUA នៅភ្នំពេញ ទស្សនាវដ្តីវៀតណាម ជាភាសាខ្មែរនៅទីក្រុង ហូជីមិញ...ព័ត៌មានជាភាសាបារាំង ១ ២៨៩ ដំណឹង ភាសាអង់គ្លេស១ ៦៦៩ ដំណឹង រូបថត ៣១៤៣រូប និងបញ្ចូលគេហទំព័ររបស់ខ្លួនជាមួយនឹងព័ត៌មានជាភាសាខ្មែរ ៥ ៣៣៤ ដំណឹង ភាសាបារាំង ១២៨៩ ដំណឹង ភាសាអង់គ្លេស ១ ៦៦៩ ដំណឹង និងរូបថតជាភាសាអង់គ្លេស២ ៤៦៧រូប ថែមទៀត ។ ទទួលដំណឹងពី VNA ជាភាសាបារាំង ១ ៩៣១ ដំណឹង Yonhap ភាសាអង់គ្លេស ១ ៨៩៣ ដំណឹង Xinhua ភាសាអង់គ្លេស ២ ៤៩៣ ដំណឹង ។ បោះពុម្ពព្រឹត្តបត្រប្រចាំថ្ងៃបាន ១៦ ៣៧៥ ច្បាប់ ឯកសារ ១ ៧៣៦ ច្បាប់ ។

ចេញផ្សាយ និងបោះពុម្ពទស្សនាវដ្តីបានចំនួន ១១លេខ គឺពីលេខ ៧៩ ដល់ ៨៩ ក្នុងនោះ ពីលេខ៧៩ ដល់ លេខ ៨៦ បោះពុម្ព ១០០០ច្បាប់ក្នុងមួយលេខ ដោយបោះពុម្ព ស-ខ្មៅ លាយពណ៌ និងពណ៌ទាំងស្រុង ពីលេខ ៨៧ ដល់ ៨៩ បោះពុម្ពពណ៌ទាំងស្រុងចំនួន ១៥០០ច្បាប់ ក្នុងមួយលេខ សរុបឆ្នាំ ២០០៩កន្លងទៅនេះ យើងបោះពុម្ពទស្សនាវដ្តីបានចំនួន ១២ ០០០ច្បាប់។ ចំណែកឯការចែកចាយ យើងបានចែកចាយតាមគ្រប់ក្រសួង និងស្ថាប័នរដ្ឋចំនួន ៤៣ស្ថាប័ន មន្ទីរព័ត៌មាន រាជធានី-ខេត្ត ទាំង ២៤ និងចែកតាមរយៈ ទំនាក់ទំនងការងារមួយចំនួនទៀត ហើយប៉ុន្មានលេខចុងក្រោយនេះ យើងបានពង្រីកការចែកចាយដល់សាកលវិទ្យាល័យ ក្នុងរាជធានីភ្នំពេញចំនួន ៥៣ សាកលវិទ្យាល័យថែមទៀត ។

ឆ្នាំ ២០០៩ ទស្សនាវដ្តីកម្ពុជា ស្ថិតក្នុងដំណាក់កាល នៃការធ្វើកំណែទម្រង់ទាំងសោភ័ណភាព ខ្លឹមសារ ការបង្កើនទំព័រ ការបង្កើនចំនួនបោះពុម្ព ដោយចាប់ផ្តើមពីបោះពុម្ព ស-ខ្មៅផង ពណ៌ផង មកពណ៌ទាំងស្រុង និង ដោយបង្កើនពី ៤៤ទំព័រ មក ៦៨ទំព័រ និងកំពុងឈានទៅដល់ ១០០ទំព័រ នៅក្នុងឆ្នាំ ២០១០ នេះ ។

## ៤- <u>**មន្ទីរព័ត៌មានខេត្ត~រាជធានី**</u>

បានដំណើរការចុះយកព័ត៌មាន ថតរូបយកមកនិពន្ធចងក្រងអត្ថបទព័ត៌មាន ផលិត កម្មវិធីផ្សេងៗនិងស្ពត អប់រំខ្លីៗ...ដើម្បីផ្សព្វផ្សាយតាមវិទ្យុបណ្តាញ វិទ្យុ FM ទូរទស្សន៍ ទូរទស្សន៍ខ្សែកាបឯកជន នៅក្នុងរាជធានី-ខេត្ត របស់ខ្លួន និងបានផ្ញើមកវិទ្យុ ទូរទស្សន៍ជាតិកម្ពុជា និងឯកជននៅភ្នំពេញ ឱ្យជួយផ្សព្វផ្សាយថែមទៀតផង ។ ទន្ទឹមនេះ គ្រប់មន្ទីរព័ត៌មានក៏បានយកចិត្តទុកដាក់ខ្ពស់ក្នុងការចាក់ផ្សាយបន្តពីវិទ្យុ ទូរទស្សន៍ជាតិកម្ពុជា ជាប្រចាំតាមរយៈ វិទ្យុ FM ទូរទស្សន៍ ទូរទស្សន៍ខ្សែកាប រាជធានី-ខេត្ត នូវព្រឹត្តិការណ៍ និងព័ត៌មានសំខាន់ៗ របស់ប្រមុខរាជរដ្ឋាភិបាល និងធ្វើការត្រួតពិនិត្យជាប្រចាំរាល់ប្រព័ន្ធផ្សព្វផ្សាយឯកជន នៅក្នុងខេត្ត ព្រមទាំងបានអនុវត្តនូវទម្លាប់ រាយការណ៍ នូវព័ត៌មានប្លែកៗ ទាន់ហេតុការណ៍ និងព្រឹត្តិការណ៍ថ្មីៗ ដែលកើតមានក្នុង មូលដ្ឋាន របស់ខ្លួនតាមរយៈ ទូរស័ព្ទ-ហ្វាក់ មកក្រសួងបានទាន់ ពេលវេលាទៀតផង ។

រយៈពេលមួយឆ្នាំនេះ បណ្តាលមន្ទីរព័ត៌មាន រាជធានី-ខេត្ត សម្រេចលទ្ធផលក្នុងការផ្សាយព័ត មានរបស់ខ្លួនដូចខាងក្រោម :

-រាជធានីភ្នំពេញ ផ្សាយតាមវិទ្យុបានចំនួន ៣ ៩៦០អត្ថបទ ទូរទស្សន៍ចំនួន ៤៦០០អត្ថបទ

-ខេត្តកណ្តាល ផ្សាយតាមវិទ្យុជាតិ៤៤អត្ថបទ ទូរទស្សន៍ជាតិ ២៣៩អត្ថបទ វិទ្យុឯកជន ១៣២ អត្ថបទ ទូរទស្សន៍ឯកជន ១៦៥ ។

-ខេត្តព្រៃវែង ផ្សាយតាមវិទ្យុជាតិ និងវិទ្យុឯកជន នៅភ្នំពេញ ៧០អត្ថបទ ទូរទស្សន៍ជាតិ ទូរទស្សន៍ឯកជន ៧២អត្ថបទ ។

-ខេត្តស្វាយរៀង ផ្សាយតាមវិទ្យុ ៧០អត្ថបទ វិទ្យុជាតិ ២៨៥អត្ថបទ វិទ្យុឯកជន ៣០២អត្ថបទ ទូរទស្សន៍ជាតិ ៦១អត្ថបទ ទូរទស្សន៍ឯកជន ៧២អត្ថបទ ។

-ខេត្តកំពង់ចាម ផ្សាយតាមវិទ្យុ ២៩៧លើក វិទ្យុជាតិ និងវិទ្យុឯកជន ២៣៣អត្ថបទ ទូរទស្សន៍ជាតិ ១២៣អត្ថបទ ។

-ខេត្តក្រចេះ ផ្សាយតាមវិទ្យុ ៩១២៣លើក ទូរទស្សន៍ជាតិ ១២៣អត្ថបទ ។

-ខេត្តមណ្ឌលគីរី ផ្សាយតាមវិទ្យុជាតិ ១៨ អត្ថបទ ទូរទស្សន៍ជាតិ ១៤អត្ថបទ ។

-ខេត្តស្ទឹងត្រែង ផ្សាយតាមវិទ្យុជាតិ ១៤៧ អត្ថបទ ទូរទស្សន៍ជាតិ ១៤០អត្ថបទ ។

-ខេត្តព្រះវិហារ ផ្សាយតាមវិទ្យុ ៣០ អត្ថបទ ទូរទស្សន៍ជាតិ និងទូរទស្សន៍ឯកជន ៧១អត្ថបទ ។

-ខេត្តសៀមរាប ផ្សាយតាមវិទ្យុ ២៨ អត្ថបទ វិទ្យុជាតិ ៣៣អត្ថបទ ទូរទស្សន៍ជាតិ ២០អត្ថបទ ។

-ខេត្តឧត្តរមានជ័យ ផ្សាយតាមវិទ្យុជាតិ ៤៩ អត្ថបទ ទូរទស្សន៍ជាតិ ១០១អត្ថបទ ។

-ខេត្តបាត់ដំបង ផ្សាយតាមវិទ្យុ ៧៨៦ អត្ថបទ ផ្ញើមកវិទ្យុជាតិ ១៤៤លើក ។

-ខេត្តបន្ទាយមានជ័យ ផ្សាយតាមវិទ្យុឯកជន ៣១០អត្ថបទ ទូរទស្សន៍ឯកជន ១៨០អត្ថបទ ។

-ខេត្តប៉ៃលិន ផ្សាយតាមវិទ្យុ ១៤៧ លើក ទូរទស្សន៍ជាតិ ១៤០អត្ថបទ ទូរទស្សន៍ឯកជន ១៣០អត្ថបទ ។

-ខេត្តពោធិសាត់ ផ្សាយតាមវិទ្យុ៣៦០លើក ទូរទស្សន៍ ២២លើក ទូរទស្សន៍ជាតិ៣៤អត្ថបទ ទូរទស្សន៍ឯកជន ៣០ អត្ថបទ ។

-ខេត្តកោះកុង ផ្សាយតាមវិទ្យុ៣៧៨០ម៉ោង ទូរទស្សន៍ជាតិ ៦២៧អត្ថបទ ។

-ខេត្តកំពង់ឆ្នាំង ផ្សាយតាមវិទ្យុ៧២០ម៉ោង វិទ្យុឯកជន ១៦០២អត្ថបទ ។

-ខេត្តកំពង់ស្ពឺ ផ្សាយតាមវិទ្យុជាតិ និងវិទ្យុឯកជន ៧២ អត្ថបទ ទូរទស្សន៍ជាតិ និងទូរទស្សន៍ឯកជន ៧២ អត្ថបទ ។

-ខេត្តព្រះសីហនុ ផ្សាយតាមវិទ្យុ ៦១២០ម៉ោង ទូរទស្សន៍ជាតិ និងទូរទស្សន៍ឯកជន ១០៩៨អត្ថបទ ។

-ខេត្តកំពត ផ្សាយតាមវិទ្យុ ៣៧៤៣អត្ថបទ ទូរទស្សន៍ជាតិ ៣៤៤អត្ថបទ

-ខេត្តតាកែវ ផ្សាយតាមវិទ្យុ ៤៣៨០អត្ថបទ វិទ្យុជាតិ ៩១៨អត្ថបទ ទូរទស្សន៍ជាតិ១២២ និងទូរទស្សន៍ឯកជន ១៩៥អត្ថបទ ។ ចំពោះខេត្តដែលមិនទាន់មានស្ថានីយ៍វិទ្យុ ទូរស្សន៍បានស្នើសុំឧបករណ៍បច្ចេកទេសវិទ្យុ ទូរទស្សន៍ និងក្រុមបច្ចេកទេសជំនាញចុះបង្ហាត់បង្ហាញដល់មូលដ្ឋាន ដើម្បីខេត្តមានលទ្ធភាពគ្រប់គ្រាន់ និងដំណើរការផ្សាយនូវព័ត៌មាន និងសកម្មភាព របស់ថ្នាក់ដឹកនាំ ក្នុងខេត្តបានទាន់ពេលវេលា ។

**៥- <u>មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ - ការិយាល័យ អ៊ីនធឺណេត</u>**

**១-** នៅក្នុងឆ្នាំ ២០០៩ នេះ បានដំណើរការការងារមានភាពល្អប្រសើរដោយមានការឧបត្ថម្ភគាំទ្រយ៉ាងជិតស្និទ្ធ ពីថ្នាក់ដឹកនាំ ក្រសួង និងអង្គការនានាទាំងក្នុង និងក្រៅប្រទេស ។

រយៈពេលមួយឆ្នាំកន្លងមកនេះ មជ្ឈមណ្ឌលបានរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលបានចំនួន ០៣វគ្គ គឺ៖

ជំនាញអ្នកនាំពាក្យសម្រាប់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ សិក្ខាកាម ២២នាក់ និង មន្ត្រីស៊ីវិល នៃរាជរដ្ឋាភិបាលកម្ពុជា ចំនួន ២៦នាក់, ការផលិតហ្វីលឯកសារវិទ្យាសាស្ត្រ សិក្ខាកាម ១៥នាក់, និងបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មានរូបថត សិក្ខាកាម ៥០នាក់ ។ បានបញ្ជូនមន្ត្រីចំនួន ០៣នាក់ ទៅចូលរួមសិក្ខាសាលា ស្តីពីបច្ចេកទេសសារគមនាគមន៍ សម្រាប់មន្ត្រីស៊ីវិលកម្ពុជា និងជំនាញបង្រៀន ភាសាអង់គ្លេស នៅមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈសិង្ហបូរី ។

**២-ការិយាល័យអ៊ិនធឺណេត** ចាប់ផ្តើមដំណើរការ ចាប់ពីថ្ងៃទី ០១ មករា ឆ្នាំ ២០០៩ រហូតមកទល់បច្ចុប្បន្ន មានភារកិច្ចស្រាវជ្រាវ ឯកសារ ផលិតឯកសារ ៖

- បានប្រើប្រាស់អ៊ិនធឺណេតសរុប ចំនួន ៣៩ ៦៨៣នាទី ត្រូវជា ៦៦១ម៉ោង ២៣នាទី
- មន្ត្រី -អ្នកសារព័ត៌មាន និងនិស្សិត ចំនួន ៥៧០នាក់ បានប្រើប្រាស់អ៊ិនធឺណេត ដោយយកព័ត៌មាន ៦៩៥លើក ផ្ញើសារ ២៩៦ លើក និងស្រាវជ្រាវឯកសារ ៥៦១លើក សរុប ១ ៥៥២ លើក
- ផលិតឯកសារបាន ២ ៤៦៤ទំព័រ និងបោះពុម្ពលិខិតបម្រើការងារក្រសួងបាន ២ ៩៨៤ទំព័រ សរុប ៥ ៤៤៨ទំព័រ

## ៦. ផ្នែកការងារយេនឌ័រ :

ក្រសួងព័ត៌មាន បានកែសម្រួល និងបំពេញបន្ថែមសមាសភាពក្រុមការងារយេនឌ័រសម្រាប់ក្រសួង ដើម្បី ប្រសិទ្ធភាពការងារឆ្លើយតបទៅនឹងគោលនយោបាយសមាសភាពយេនឌ័រ របស់រាជរដ្ឋាភិបាល ព្រមទាំងបានបញ្ចូលផែនការ សកម្មភាពការងារយេនឌ័រ ទៅក្នុងផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំ របស់ក្រសួងព័ត៌មាន និងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ។ ក្រសួងក៏បានយកចិត្ត ទុកដាក់កសាងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍន៍ធនធានមនុស្ស ដោយ ផ្តល់អាទិភាព ផ្តល់ឱកាស និងលើកទឹកស្ត្រីនៅក្នុងស្ថាប័ន ក្នុងការតម្លើងឋានៈតួនាទី ការប្រឡងមន្ត្រីក្របខណ្ឌថ្មី និងលើកកម្ពស់ សមត្ថភាពជំនាញដល់នារី ដែលកំពុងបំពេញការងារក្នុងប្រពន្ធផ្សព្វផ្សាយទាំងរដ្ឋ និង ឯកជន ។ ទន្ទឹមនឹងនេះ ក៏បានលើកទឹកចិត្ត បង្កើនកម្មវិធីផ្សាយព័ត៌មាន និងការអប់រំលើគ្រប់វិស័យ ជាពិសេសបញ្ហាស្ត្រី និងកុមារ ក្នុងកម្មវិធីផ្សាយរបស់ វិទ្យុ ទូរទស្សន៍ និងសារព័ត៌មានបោះពុម្ពទៀតផង ។

**សកម្មភាពជាក់ស្តែង ៖**

- បើកវគ្គបណ្តុះបណ្តាល គ្រូបង្គោលស្ត្រី សម្រាប់វិស័យព័ត៌មានចំនួន ១៣នាក់ មកពីស្ថានីយវិទ្យុ ទូរទស្សន៍នានា រយៈពេល ១០ ថ្ងៃ ។
- បើកវគ្គបណ្តុះបណ្តាល ផ្នែកជំនាញ អានព័ត៌មាន អត្ថាធិប្បាយ បញ្ចូលសម្លេងភាពយន្ត spot សម្រាប់វិទ្យុ-ទូរទស្សន៍ជាតិកម្ពុជា និងវិទ្យុ-ទូរទស្សន៍ឯកជន បានចំនួន ១៩នាក់។
- បើកវគ្គបំប៉ន របៀបប្រើកាមេរ៉ា និងថតប្លង់រូបភាពចំនួន ២៣នាក់ និងវគ្គបំប៉នស្តីពីការផលិតខ្សែភាពយន្តសម្រាប់ទូរទស្សន៍ របៀបដឹកនាំរឿង សរសេររឿង ថតរូបភាពទំនាក់ ទំនង ការងារ និង គ្រប់គ្រងថវិការចំនួន ១៥ នាក់ ។
- បានផ្សព្វផ្សាយ និងផលិតរឿងខ្លី ***"សេវាជួយជនរងគ្រោះ ករណីសង្ស័យរំលោភផ្លូវភេទ"*** រៀបចំដោយក្រសួង កិច្ចការនារី និងកម្មវិធី សំនួរ-ចម្លើយ រៀបចំដោយគណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌ សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ បានចំនួន ០៤ កម្មវិធី សម្រាប់ត្រីមាសទី៤ ឆ្នាំ ២០០៩ នេះ ។
- ចេញសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ ចំពោះគ្រប់ស្ថានីយ៍ទាំងអស់ ដែលកំពុងដំណើរការ ផ្សព្វផ្សាយនៅក្នុងព្រះរាជណាចក្រកម្ពុជា ឱ្យខិតខំបន្តការអនុវត្តន៍នូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការលើកកម្ពស់សេចក្តីថ្លៃថ្នូរ និងសីលធម៌វិជ្ជាជីវៈរបស់ស្ថានីយ៍នីមួយៗ ជាពិសេស ដើម្បីរក្សានូវឧត្តមភាព នៃប្រពៃណីនិង ទំនៀមទំលាប់ ដ៏ល្អរបស់សង្គមជាតិដោយការប្រយ័ត្នប្រយែង ក្នុងការថត និងផ្សាយនូវ រូបភាព ដែលនាំអោយមានការវាយតម្លៃមិនល្អ ពីសាធារណជន ដូចជាទម្លាប់ថតមន្ត្រីមួយចំនួន ដែលស្ថិតក្នុងស្ថានភាព ឬ កាយ វិការមិនសមស្របនៅក្នុងពេល *ប្រជុំផ្លូវការនានា និងការថតសម្ភាសន៍ នារីខ្មែរ ដែលអង្គុយគងអន្ទាក់ខ្លា ស្លៀកពាក់មិនសមរម្យ ជាដើម ។*

III. **បញ្ហាប្រឈម**

-មូលដ្ឋានសម្ភារៈ បច្ចេកទេស ស្ថានីយ៍ផ្សព្វផ្សាយ វិទ្យុ-ទូរទស្សន៍នៅថ្នាក់កណ្តាល កាន់តែថមថយគុណភាពបច្ចេកទេស ។ ការកសាង វិទ្យុ-ទូរទស្សន៍ (ថ្នាក់ក្រោមជាតិ) នៅតាមខេត្ត មានការយឺតយ៉ាវ ដោយ ខ្វះទុនវិនិយោគ ។

-វិសាលភាពនៃប្រពន្ធផ្សព្វផ្សាយរបស់រាជរដ្ឋាភិបាល នៅពុំទាន់បានគ្របដណ្តប់បានពេញលេញ ជាពិសេសនៅតាមជនបទដាច់ស្រយាល ។ ប្រជាជនមួយចំនួននៅខ្វះខាតលទ្ធភាព និងមធ្យោបាយ ព្រមទាំងពេលវេលា ដើម្បីទទួលព័ត៌មានពីថ្នាក់ ជាតិ ទន្ទឹមនិងនេះ រដ្ឋនៅពុំទាន់ភាពលទ្ធភាព និង មធ្យោបាយគ្រប់គ្រាន់ដើម្បីទទួលបាននូវព័ត៌មានឆ្លើយតបពីប្រជាជន អំពីស្ថានភាព នៃជីវភាពរស់នៅ និងទិដ្ឋភាពនៃសង្គម របស់សហគមន៍នៅមូលដ្ឋាននៅឡើយ ។

-សមត្ថភាពរបស់ស្ថាប័ន និងធនធានមនុស្សពុំទាន់ឆ្លើយតបនឹងស្ថានភាពវិវត្តន៍រីកចំរើន ដ៏ជឿនលឿនរបស់បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ។

-ការខ្វះខាតមូលដ្ឋានសម្ភារៈ ថវិកាដំណើរការ និងបៀវត្សតិចតួច កំពុងប្រឈមនិងការប្រកួតប្រជែង ជាមួយវិស័យ ឯកជន ជាពិសេសការបែកខ្ញែក អ្នកមើល អ្នកស្តាប់ និងអ្នកអាន ។

-ច្បាប់ស្តីពីរបបសារព័ត៌មាន ពុំទាន់ឆ្លើយតបបានពេញលេញ ចំពោះមុខសភាពការណ៍វិវត្តន៍ រីកចម្រើនរបស់ វិស័យព័ត៌មាន និងសោតទស្សន៍ ដែលទាមទារនូវការកសាងលិខិតបទដ្ឋានគតិយុត្តិថ្មី ស្របតាមសភាពការណ៍ ។

-ខ្វះលិខិតបទដ្ឋានគតិយុត្តិសម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោទស្សន៍ ។

IV- **សេចក្តីសន្និដ្ឋាន**

ឆ្នាំ ២០០៩ កន្លងទៅនេះ ប្រព័ន្ធផ្សព្វផ្សាយគ្រប់ផ្នែកក្នុងព្រះរាជណាចក្រកម្ពុជាកាន់តែមានការរីកចម្រើនទាំងបរិមាណ គុណភាព និងវិសាលភាព និងជំរុញអោយវិស័យព័ត៌មាន និងសោតទស្សន៍កាន់តែមានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មាន ក្នុងការផ្តល់ ចំនេះដឹង ការអប់រំ ផ្តល់ការកំសាន្តជូនប្រជាពលរដ្ឋ គ្រប់ទិស ទីទាំងនៅក្នុងស្រុកនិងក្រៅប្រទេស ។ ប្រព័ន្ធផ្សព្វផ្សាយគ្រប់ផ្នែក បានរួមចំណែកយ៉ាងធំធេង ក្នុងការពង្រឹក លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធមនុស្ស និងបានឆ្លុះបញ្ចាំងអោយឃើញពីសិទ្ធិសេរីភាពក្នុង ការបញ្ចេញមតិ សិទ្ធិសេរីភាពនៃសារព័ត៌មាន ។ ទិសស្លោក “ **ឆ្អែក លឿន ទុកចិត្តបាន នៅទីណា ពេលណាក៏បាន** ” បានក្លាយជា ផែនទីបង្ហាញផ្លូវផងជាគោលការណ៍ពង្រឹងពង្រីកវិជ្ជាជីវៈរបស់អ្នកសារព័ត៌មានគ្រប់ផ្នែកផង ជាមោទភាពនៃ ប្រព័ន្ធផ្សព្វផ្សាយ គ្រប់ផ្នែក ទាំងរដ្ឋ និងឯកជនផង និងជាគោលដៅ នៃប្រកួតប្រជែង ក្នុងការផ្តល់សេវា ផ្សព្វផ្សាយរបស់អង្គភាពផ្សព្វផ្សាយ ទាំងអស់ផង ។

ដោយឡែក ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ដែលស្ថិតក្រោមការដឹកនាំរបស់ ក្រសួងព័ត៌មាន ទាំងនៅថ្នាក់កណ្តាលទាំងនៅថ្នាក់ រាជធានី-ខេត្ត ទាំងវិទ្យុ-ទូរទស្សន៍ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP ទស្សនាវដ្តីសុទ្ធតែបាន បង្កើនគុណភាព និងវិសាលភាព នៃការផ្សព្វផ្សាយរបស់ខ្លួន ដោយមានទទួលខុសត្រូវ និងថ្នៃប្រឌិតខ្ពស់បំផុត ។

លទ្ធផលការងារដ៏គួរឱ្យមោទនភាព នាឆ្នាំ ២០០៩ កន្លងទៅ គឺជាផ្លែផ្កា នៃគំនិតដឹកនាំ ដ៏ឈ្លាសវៃរបស់ថ្នាក់ដឹកនាំគ្រប់ លំដាប់ថ្នាក់ និងគ្រប់ផ្នែក ជាកិច្ចខិតខំប្រឹងប្រែងរបស់មន្រ្តីរាជការ គ្រប់លំដាប់ថ្នាក់ ដែលនៅតែមានស្មារតីតស៊ូ អត់ធ្មត់ព្យាយាម ដោយមានការទទួលខុសត្រូវលើភារកិច្ចរបស់ខ្លួន ។

V- **ទិសដៅការងារឆ្នាំ ២០១០**

-ផ្សព្វផ្សាយព្រះរាជសកម្មភាពព្រះមហាក្សត្រ សកម្មភាពព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល គ្រប់ស្ថាប័នជាតិ និងអង្គការនានា ទាំងក្នុងនិងក្រៅប្រទេស លើកិច្ចការនយោបាយជាតិ និងអន្តរជាតិ ។

-តាមដាន និងផ្សព្វផ្សាយសភាពការណ៍ ព្រឹត្តការណ៍ក្នុងប្រទេស និងលើសកលលោក

-ផ្សព្វផ្សាយពីសមិទ្ធផលថ្មីៗ របស់សង្គមជាតិលើគ្រប់វិស័យ

-ផ្សព្វផ្សាយអប់រំតាមរយៈកម្មវិធីនានាដើម្បីផ្ដល់ចំណេះដឹងទូទៅ....និងការកំសាន្តសប្បាយជូនប្រជាពលរដ្ឋ។

-បង្កើនការដឹកនាំនិងគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ គ្រប់គ្រងការផ្ដល់ព័ត៌មានអោយបានត្រឹមត្រូវ បានឆាប់ទាន់ពេលវេលា និងបង្កើនការផលិតកម្មវិធីថ្មីៗ ជូនសាធារណជនគ្រប់មជ្ឈដ្ឋាន ។

-លើកកម្ពស់ការគ្រប់គ្រងមន្ត្រីរាជការ និងការបណ្ដុះបណ្ដាលធនធានមនុស្ស សំដៅបង្កើនគុណភាព ប្រសិទ្ធភាពការងារ ។

-ពង្រឹងក្រុមការងារកែទម្រង់ ការគ្រប់គ្រងហរិញ្ញវត្ថុសាធារណៈ របស់ក្រសួងព័ត៌មាន ដើម្បីអនុវត្តកម្ម វិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល (សេចក្ដីសម្រេចលេខ ៥៦-សសរ ចុះថ្ងៃទី ៣០-១០-២០០៧ របស់រាជរដ្ឋាភិបាល) ។

-បន្តការតាមដាន ត្រួតពនិត្យ និងកែលំអជាប្រចាំ រាល់ការផ្សាយរបស់វិទ្យុ ទូរទស្សន៍ និងការបោះផ្សាយរបស់សារព័ត៌មាននានា ក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យអនុវត្តបានត្រឹមត្រូវតាមច្បាប់ បទបញ្ជា ក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ខ្លួន គោលដៅរបស់យើង គឺចង់អោយប្រជាពលរដ្ឋទូទាំងប្រទេស ទោះជានៅតំបន់ដាច់ស្រយាលចុងកាត់មាត់ញកណាក៏ដោយ ក៏ទទួលបានដោយសមធម៌ នូវព័ត៌មានផ្លូវការ ជាព័ត៌មានត្រឹមត្រូវ ទទួលបានចំណេះដឹង និងការអប់រំប្រកបដោយ គុណធម៌ មានខ្លាតគំរូ ច្បាស់លាស់ និងទទួលបានការកំសាន្តសប្បាយដ៏ស្អាតស្អំប្រកបដោយ សីលធម៌ ។

-ជម្រុញការកសាងលិខិតបទដ្ឋានគតិយុត្តិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពដឹកនាំ និងគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ ឱ្យស្ថិតក្នុងក្របខ័ណ្ឌនីតិរដ្ឋ និងស្របតាមគោលការណ៍ លទ្ធិប្រជាធិបតេយ្យ ។

-ត្រៀមបំពាក់ម៉ាស៊ីនផ្សាយទូរទស្សន៍ថ្មីមានកម្លាំង ២០គីឡូវ៉ាត់ និងម៉ាស៊ីនផ្សាយបំរុង ៥គីឡូវ៉ាត់ នៅស្ថានីយទួលគោក ដែលជាមជ្ឈមណ្ឌលកណ្ដាល ។

-ត្រៀមបំពាក់ម៉ាស៊ីនផ្សាយវិទ្យុ FM ខេត្តសៀមរាប កម្លាំង ៥គីឡូវ៉ាត់ សំដៅបម្រើការផ្សាយដំណឹងការអប់រំ និងការកំសាន្ត ជូនប្រជាពលរដ្ឋក្នុងតំបន់ទេសចរណ៍ នឹងតំបន់បឹងទន្លេសាប និងម៉ាស៊ីន FM ២គីឡូវ៉ាត់ សម្រាប់ ៤ ខេត្តទៀត ។